Intention to apply for Year 5 placement in an opportunity class

Information for metropolitan/regional applicants

# គោលបំណងដើម្បីដាក់ពាក្យសុំកន្លែងរៀនថ្នាក់ទី៥ ក្នុងថ្នាក់សិស្សមានទេពកោសល្យ

## ព័ត៌មានសម្រាប់អ្នកដាក់ពាក្យសុំពីតំបន់ជុំវិញក្រុង/តំបន់ភូមិភាគ

សូមគោរពឪពុកម្ដាយ/អ្នកថែទាំ

ថ្នាក់សិស្សមានទេពកោសល្យ រៀបចំសម្រាប់សិស្សដែលមានទេពកោសល្យ និងសក្ដានុពលខ្ពស់ប្រកបដោយបញ្ញាវាងវៃ បើមិនដូច្នោះទេ ពួកគេប្រហែលជាអាចមិនមានមិត្តរួមថ្នាក់គ្រប់គ្រាន់នៅកម្រិតសិក្សា និងសង្គមរបស់ពួកគេផ្ទាល់ឡើយ។ ជាធម្មតា សិស្សដែលបានទទួលកន្លែងរៀនដោយជោគជ័យ នឹងត្រូវតែចាកចេញពីសាលាបច្ចុប្បន្នរបស់ពួកគេ ដើម្បីចុះឈ្មោះចូលរៀននៅសាលាដែលមាន ថ្នាក់សិស្សមានទេពកោសល្យសម្រាប់ថ្នាក់ទី៥ និងទី៦។

### ការធ្វើតេស្ត និងការវាយតម្លៃ

ពាក្យសុំកន្លែងរៀននៅថ្នាក់សិស្សមានទេពកោសល្យ ត្រូវបានពិចារណាលើលទ្ធផលនៃការធ្វើតេស្តសុំកន្លែងរៀន នៅថ្នាក់សិស្សមានទេពកោសល្យតែមួយគត់។ សិស្សដែលប្រាថ្នាចង់ឱ្យគេពិចារណាផ្តល់កន្លែងរៀន ត្រូវបានតម្រូវឱ្យអង្គុយធ្វើតេស្តសុំកន្លែងរៀននៅថ្នាក់សិស្សមានទេពកោសល្យ តាមកាលបរិច្ឆេទដែលបានបង្ហាញនៅលើទំព័របណ្ដាញខាងក្រោម។ https://education.nsw.gov.au/public-schools/selective-high-schools-and-opportunity-classes/general-information/key-dates-

### របៀបដាក់ពាក្យសុំ

អ្នកដាក់ពាក្យសុំត្រូវតែដាក់ពាក្យសុំតាមអនឡាញ នៅរវាងកាលបរិច្ឆេទនានាដែលបានបង្ហាញនៅលើទំព័រកាលបរិច្ឆេទសំខាន់ៗ នៅតាមគេហទំព័រ https://education.nsw.gov.au/public-schools/selective-high-schools-and-opportunity-classes/general-information/key-dates-

ពាក្យសុំអាចរកបាននៅតាមគេហទំព័រ https://education.nsw.gov.au/oc

ឪពុកម្ដាយត្រូវតែប្រើអាសយដ្ឋានអ៊ីមែលផ្ទាល់ខ្លួនរបស់ពួកគេ ហើយមិនមែនជាកម្មសិទ្ធិរបស់កូនទេ។ ជាធម្មតា ការដាក់ពាក្យសុំយឺតមិនត្រូវបានទទួលយកទេ។

ឪពុកម្ដាយដែលមិនអាចចូលប្រើប្រាស់អ៊ីនធឺណិត អាចដាក់ពាក្យសុំបាននៅតាមបណ្ណាល័យសាធារណៈ។ ប្រសិនបើអ្នកមានពិការភាពដែលរារាំងអ្នកពីការប្រើប្រាស់កុំព្យូទ័រ អ្នកអាចទាក់ទងមកអង្គភាពដើម្បីទទួលបានជំនួយបន្ទាប់ពីពាក្យសុំបានបើក។

អ្នកត្រូវតែដាក់ពាក្យសុំតែ**មួយ**ប៉ុណ្ណោះ សម្រាប់សិស្សម្នាក់ៗ។

ទម្រង់បែបបទខាងក្រោម **មិនមែន**ជាពាក្យសុំទេ វាជាដំបូន្មានដល់សាលារៀនដែលអ្នកមានបំណងដាក់ពាក្យសុំ។ សាលារៀន**មិនអាច**ដាក់ពាក្យសុំជំនួសអ្នកបានទេ។

ដោយសេចក្ដីរាប់អាន

នាយកសាលា

Intention to apply for Year 5 placement in an opportunity class

For completion by metropolitan/regional applicants

# គោលបំណងដើម្បីដាក់ពាក្យសុំកន្លែងរៀនថ្នាក់ទី៥ ក្នុងថ្នាក់សិស្សមានទេពកោសល្យ

## សម្រាប់បំពេញដោយអ្នកដាក់ពាក្យសុំពីតំបន់ជុំវិញក្រុង/តំបន់ភូមិភាគ

**នេះមិនមែនជាពាក្យសុំចូលរៀនថ្នាក់សិស្សមានទេពកោសល្យទេ។**

នេះជាការជូនដំណឹងដល់សាលាបឋមសិក្សារបស់អ្នក ដែលអ្នកមានបំណងដាក់ពាក្យសុំ។

ដើម្បីដាក់ពាក្យសុំ សូមចូលទៅកាន់ទម្រង់បែបបទតាមអនឡាញ នៅតាមគេហទំព័រ https://education.nsw.gov.au/oc

*សូមបំពេញព័ត៌មានខាងក្រោមជាភាសាអង់គ្លេស ហើយប្រគល់ជូនដល់សាលាបឋមសិក្សារបស់អ្នកវិញ។*

ឈ្មោះសិស្ស

ថ្នាក់រៀន

ខ្ញុំមានបំណងដាក់ពាក្យសុំកន្លែងរៀននៅថ្នាក់ទី៥ឆ្នាំក្រោយ ក្នុងថ្នាក់សិស្សមានទេពកោសល្យសម្រាប់កូនរបស់ខ្ញុំ។ ខ្ញុំដឹងថា ខ្ញុំត្រូវដាក់ពាក្យសុំតាមតាមអនឡាញ នៅរវាងកាលបរិច្ឆេទនានាដែលបានបង្ហាញនៅលើទំព័រកាលបរិច្ឆេទសំខាន់ៗ នៅតាមគេហទំព័រ https://education.nsw.gov.au/public-schools/selective-high-schools-and-opportunity-classes/general-information/key-dates-

ឈ្មោះឪពុកម្ដាយ/អ្នកថែទាំ (សូមសរសេរអក្សរពុម្ព)

ហត្ថលេខាឪពុកម្ដាយ/អ្នកថែទាំ

## សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទូរសព្ទទៅនាយកសាលារបស់អ្នក។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយក្នុងការសាកសួររបស់អ្នក សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ តាមលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ សូមប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ពេលនោះការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយអ្នកក្នុងការសន្ទនា។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។